ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

ការិយាល័យអ្នកនាំពាក្យ

លេខ ៣២៦ សប្រក

# សេចក្តីប្រកាសព័ត៌មាន

## ស្តីពីសម័យប្រជុំពេញអង្គរបស់គណៈរដ្ឋមន្ត្រី

## ថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ២០០៥

ថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ២០០៥ វេលាម៉ោង ៨:៣០ នាទី នៅទីស្តីការគណៈរដ្ឋមន្ត្រី មានបើកសម័យប្រជុំពេញអង្គរបស់គណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតរបស់ សម្តេច **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ដើម្បីឆ្លង :

**១-សេចក្តីព្រាងច្បាប់ស្តីពីជីវសុវត្ថិភាព**

**២-បញ្ហាផ្សេងៗ** : សុំការយល់ព្រមពីគណៈរដ្ឋមន្ត្រី ដើម្បីសុំការអនុម័តពីស្ថាប័ននីតិប្បញ្ញត្តិលើ "កិច្ចព្រមព្រៀងសហប្រតិបត្តិការក្នុងតំបន់ ស្តីពីការប្រយុទ្ធប្រឆាំងអំពើប្លន់នាវា និងអំពើប្លន់ប្រដាប់អាវុធក្នុងដែនសមុទ្រអាស៊ី" ។

ក្រោយពីបានពិភាក្សា និងផ្លាស់ប្តូរយោបល់រួចមក អង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីបានសំរេចឯកភាព :

### I- លើសេចក្តីព្រាងច្បាប់ស្តីពីជីវសុវត្ថិភាព

សេចក្តីព្រាងច្បាប់នេះត្រូវបានរៀបចំឡើងដោយក្រសួងបរិស្ថានក្រោមជំនួយបច្ចេកទេសពីមូលនិធិបរិស្ថានពិភពលោក និងកម្មវិធីបរិស្ថានសហប្រជាជាតិ ដោយផ្អែកតាមស្មារតីនៃពិធីសារកាតាហ្សេណា ស្តីពីជីវសុវត្ថិភាព និងសំរាប់ជាតំរូវការចាំបាច់របស់ព្រះរាជាណាចក្រកម្ពុជា ។ ដើម្បីទប់ស្កាត់ហានិភ័យដែលបណ្តាលមកពីការប្រើប្រាស់សារពាង្គកាយកែច្នៃរស់ (**Living Modified Organism- "LMOs"**) ។ សេចក្តីព្រាងនេះមានគោលបំណង :

- អនុវត្តនូវគោលការណ៍ប្រុងប្រយ័ត្នស្តីពីជីវសុវត្ថិភាព
- ទប់ស្កាត់ផលប៉ះពាល់អវិជ្ជមានទៅលើការអភិរក្សជីវៈចំរុះ និងធនធានធម្មជាតិ
- ធានាប្រសិទ្ធិភាពនៃការអភិរក្ស និងការប្រើប្រាស់ជីវៈចំរុះដោយនិរន្តរភាព ព្រមទាំងយកចិត្តទុកដាក់ចំពោះហានិភ័យដល់សុខភាពមនុស្ស

-ធ្វើអោយមានតម្លាភាពក្នុងនីតិវិធីពិនិត្យ និងក្នុងការធ្វើសេចក្តីសំរេចចំពោះសារពាង្គកាយកែច្នៃរស់ និងសកម្មភាពទាំងឡាយដែលទាក់ទងនឹងសារពាង្គកាយកែច្នៃរស់

-លើកកំពស់ការយល់ដឹងអំពីជីវបច្ចេកទេសទំនើប សំដៅទប់ស្កាត់ហានិភ័យពីការប្រើប្រាស់ និងការបញ្ចេញសារពាង្គកាយកែច្នៃរស់នៅក្នុងបរិស្ថាន និងសុខភាពមនុស្ស ។

សេចក្តីព្រាងច្បាប់ស្តីពីសុវត្ថិភាពជាតិ ចែកចេញជា ១១ ជំពូក និង ៤៥ មាត្រា ដែលគោលដៅនៃច្បាប់ គឺដើម្បីរួមវិភាគទានក្នុងការធានាកំរិតការពារអោយបានសមស្របនៅក្នុង ការផ្ទេរ ការគ្រប់គ្រង និងការប្រើប្រាស់អោយមានសុវត្ថិភាពនៃសារពាង្គកាយកែច្នៃរស់ ដែលជាលទ្ធផលនៃជីវបច្ចេកវិទ្យាទំនើប អាចនាំមកនូវផលប៉ះពាល់អវិជ្ជមានដល់ការអភិរក្ស និងការប្រើប្រាស់ដោយនិរន្តរភាពនូវធនធានជីវចំរុះ ដោយគិតគូអំពីហានិភ័យដល់សុខភាពមនុស្ស និងជាពិសេសផ្តោតការចាប់អារម្មណ៏សំខាន់ទៅលើចលនាឆ្លងដែនផងដែរ ដែលរួមចំណែកក្នុងការអភិវឌ្ឍន៏សេដ្ឋកិច្ចជាតិ និងកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនស្របតាមគោលនយោបាយចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា ។

## II~អំពីបញ្ហាផ្សេងៗ

អង្គប្រជុំគណៈរដ្ឋមន្ត្រី បានឯកភាពបញ្ជូន "កិច្ចព្រមព្រៀងសហប្រតិបត្តិការក្នុងតំបន់ ស្តីពីការប្រយុទ្ធប្រឆាំងអំពើប្លន់នាវា និងអំពើប្លន់ប្រដាប់អាវុធក្នុងដែនសមុទ្រអាស៊ី" ទៅស្ថាប័ននីតិប្បញ្ញត្តិដើម្បីសុំសច្ចាប័ន។

-ទន្ទឹមនឹងនេះ អង្គប្រជុំគណៈរដ្ឋមន្ត្រីបានឯកភាពក្នុងស្មារតីមនុស្សធម៌ ផ្តល់ថវិកា ២០.០០០ ដុល្លារអាមេរិក (ពីរម៉ឺនដុល្លារអាមេរិកគត់) ជួយដល់ជនរងគ្រោះដោយខ្យល់ព្យុះកាទ្រីណា ដែលបានបោកបក់ប៉ះទៅលើរដ្ឋមួយចំនួននៅសហរដ្ឋអាមេរិក ។

អង្គប្រជុំគណៈរដ្ឋមន្ត្រីបានបិទសម័យប្រជុំនៅម៉ោង ១០ និង ១៥ នាទី ។

ភ្នំពេញ, ថ្ងៃទី ០៩ ខែ កញ្ញា ២០០៥